ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

១. ថ្ងៃ ខែ ឆ្នាំ ៖ ថ្ងៃសុក្រ ២កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥។

២. **ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

៣. ប្រធាន និងសមាសភាពចូលរួម ៖

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣០រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣២រូប សរុបចំនួន៦២រូប។

៤. របៀបវារៈ៖

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បទបង្ហាញស្តីពី "ការគ្រប់គ្រង ការចាត់ចែង និងកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់" ដោយលោក **ម៉ុង ស៊ីតាណា** អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

**៥.១** ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានថ្លែងនូវមតិស្វាគមន៍ដល់អង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមការងារនៃគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក ដែលបង្កឱ្យអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅកម្ពុជាបានធ្លាក់ចុះជាបន្តបន្ទាប់មកនៅត្រឹមតែ ០,៥ % នៅឆ្នាំ២០២៤។ ទន្ទឹមនឹងនេះដែរ **ឯកឧត្តម** ក៏បានលើកផងដែរពីផលប៉ះពាល់នៃការកាត់បន្ថយហិរញ្ញប្បទានពីខាងក្រៅ។

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបើកនូវកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៥ ក្រោមប្រធានបទ "**ការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់**"។

**កិច្ចប្រជុំនេះមានគោលបំណង ដូចខាងក្រោម៖**

១-បច្ចុប្បន្នភាពនៃមេរោគអេដស៍ និងជំងឺអេដស៍ លើពិភពលោក និងកម្ពុជា។

២- សមិទ្ធផលនៃការឆ្លើយតបនឹងមេរោគអេដស៍ នៅកម្ពុជា។

៣-ការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។

៤- ផ្សេងៗ

ជាបន្ត **ឯកឧត្តមបណ្ឌិត** ក៏បានបញ្ជាក់រំលឹកឡើងវិញពីការប្រឹងប្រែងចូលរួមក្នុងការឆ្លើយតបនឹងមេរោគអេដស៍ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ចាប់តាំងពីការរកឃើញមេរោគអេដស៍ជាលើកដំបូងនៅប្រទេសកម្ពុជានាឆ្នាំ១៩៩១ ដែលទាំងលើផ្នែកបង្ការ ការព្យាបាល និងគាំទ្រ រហូតមកដល់ចុងឆ្នាំ២០២៤នេះ កម្ពុជាសម្រេចគោលដៅបាន ៩២-១០០-៩៨។ ការសម្រេចបាននូវលទ្ធផលនេះ គឺដោយសារមានការយកចិត្តទុកដាក់ពីអតីតប្រមុខរាជរដ្ឋាភិបាល **សម្តេចតេជោ ហ៊ុន សែន** ដែលបានអំពាវនាវជាចលនាជាតិតែមួយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងគិតគូប្រកបដោយគតិបណ្ឌិតរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការសម្រេចបាននូវគោលដៅជាតិបញ្ចប់ អេដស៍ និងចីរភាពកម្មវិធីអេដស៍ ព្រមទាំងមានការចូលរួមអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងផ្នែកជាតិ អន្តរជាតិ និងសង្គមស៊ីវិល ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយភាពឈ្លាសវៃថ្លៃថ្នូប្រសិទ្ធភាពរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** ក្នុងចក្ខុវិស័យឈានទៅសម្រេចបាននូវគោលដៅនៃគោលនយោបាយជាតិ៖

១- កាត់បន្ថយការចម្លងថ្មីតិចជាង ១នាក់ ឬប្រមាណជា ២០០នាក់ក្នុងមួយឆ្នាំ។

២- កាត់បន្ថយការស្លាប់ដោយសារមេរោគអេដស៍ឱ្យនៅក្រោម ២០០នាក់ក្នុងមួយឆ្នាំ។

៣- លុបបំបាត់ការមាក់ងាយ និងរើសអើង។

ទន្ទឹមនឹងជោគជ័យកន្លងមក **ឯកឧត្តមបណ្ឌិត** ក៏បានលើកឡើងពីបញ្ហាប្រឈមនៃការធ្លាក់ចុះថវិកាជំនួយ ដែលបង្កឱ្យអង្គការសង្គមស៊ីវិលមួយចំនួន ទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍បង្ខំចិត្តកាត់បន្ថយបុគ្គលិក ឬបិទការិយាល័យតែម្តង។

**៥.២** ជាបន្ត **ឯកឧត្តមបណ្ឌិត** បានអនុញ្ញាតជូនលោក **ម៉ុង ស៊ីតាណា** អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើបទបង្ហាញជម្រាបជូនដែលផ្តោតលើ៖

- ទិដ្ឋភាពទូទៅ នៃការគ្រប់គ្រងមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់

- សមាសភាគនៃមូលនិធិក្រុង ស្រុក ឃុំ សង្កាត់
- ការរៀបចំ ការអនុម័ត និងការអនុវត្ត
- គម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន
- គម្រោង ឬសកម្មភាព និងមាតិកាថវិកា
- ទិសដៅបន្តនៃការគ្រប់គ្រងមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។

ជាបន្ត លោកបានជម្រាបជូនអង្គប្រជុំថា ការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ អនុលោមទៅនឹង៖

- អនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានពីថវិកាជាតិជូនមូលនិធិក្រុង ស្រុក។
- អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានពីថវិកាជាតិជូនមូលនិធិឃុំ សង្កាត់។
- ចំណាយលើសេវាសង្គម និងអនាម័យបរិស្ថាន ជាផ្នែកមួយនៃចំណាយរបស់ធនធានមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់។

លោកក៏បានបញ្ជាក់ផងដែរថា៖ ធនធានមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ ត្រូវចែកចេញជា៣សមាសភាគដូចជា៖

- សមាសភាគរដ្ឋបាលទូទៅ។
- សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន។
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ដោយប្រើប្រាស់នូវប៉ារ៉ាម៉ែត្រចំណាយសម្រាប់សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន ៣០% នៃចំណែកស្មើគ្នា ២០% សមាមាត្រនៃចំនួនប្រជាពលរដ្ឋ ក្នុងឃុំ សង្កាត់នីមួយៗ (ទិន្នន័យក្រសួងផែនការ) និង៥០% សមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រ (ទិន្នន័យក្រសួងផែនការ)។ ការរៀបចំ ការអនុម័ត និងការអនុវត្តនៃការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ត្រូវធានាថា គម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថានត្រូវបានចាត់ជាអាទិភាព និងដាក់បញ្ចូលក្នុងផែនការវិនិយោគបីឆ្នាំរំកិល និងការរៀបចំថវិកាសេវាសង្គម និងអនាម័យបរិស្ថានប្រចាំឆ្នាំត្រូវកំណត់ទៅតាមគោលការណ៍ដែលបានកំណត់។

ជាបន្តលោក បានលើកឡើងថា មុខសញ្ញាចំណាយគម្រោង ឬសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន អាចធ្វើបច្ចុប្បន្នភាព តាមការចាំបាច់ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃសង្គមសេដ្ឋកិច្ចនិងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ដែលរួមមាន ១១ គម្រោង (សេវាសង្គមចំនួន៨ និងបរិស្ថានចំនួន ៣) ក្នុងនោះមាន៖

- ការលើកកម្ពស់សុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ
- ពង្រឹង និងពង្រីកការអប់រំកុមារតូច
- ការលើកកម្ពស់គុណភាពអប់រំបឋមសិក្សា និងមធ្យមសិក្សា
- កិច្ចការពារស្ត្រី និងកុមារ
- ការលើកកម្ពស់សមភាពយេនឌ័រ
- កិច្ចអន្តរាគមន៍គាំទ្រ និងជំរុញការអនុវត្តកិច្ចគាំពារសង្គម

- ពង្រឹងការយល់ដឹង និងទប់ស្កាត់ការរីករាលដាលជំងឺឆ្លង និងជំងឺមិនឆ្លង
- ការលើកកម្ពស់គណនេយ្យភាពសង្គម
- ទឹកស្អាត និងអនាម័យ
- ការគ្រប់គ្រងសំណល់រឹង រាវ
- ការប្រែប្រួលអាកាសធាតុ

ចុងបញ្ចប់ លោកក៏បានបង្ហាញពីសារាចរអន្តរក្រសួងលេខ ០០៧ សហវ.សអ.ហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ និងទិសដៅបន្ត។

ជាបន្ត **ឯកឧត្តមបណ្ឌិត** ផ្តល់ពេលវេលាជូនអង្គប្រជុំពិភាក្សា និងសំណួរចម្លើយទាក់ទងនឹងការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិស្រុក និងមូលនិធិឃុំ សង្កាត់។

បន្ទាប់ពីពិភាក្សាយ៉ាងផុលផុស ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** ស្នើសុំក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ លើកការងារអេដស៍ចូលក្នុងផែនការរបស់ខ្លួន។

ទន្ទឹមនឹងនោះ **ឯកឧត្តមបណ្ឌិត** បានរំលឹកឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤-២០២៨ ដែលមានចក្ខុវិស័យ៖ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញ គ្មានមេរោគអេដស៍ និងជំងឺអេដស៍ គ្មានការមាក់ងាយ រើសអើង និងមានបេសកកម្មធានាបាននូវការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍បានល្អ ដែលមានការចូលរួមប្រកបដោយបរិយាបន្នមូលដ្ឋាន និងសហគមន៍ជាម្ចាស់ ផ្តោតលើប្រជាពលរដ្ឋជាធំ មានភាពធន់ និងមានចីរភាព ដោយមានគោលដៅ ការឆ្លើយតបនឹងមេរោគអេដស៍ជាពហុវិស័យប្រកបដោយចីរភាពដែលធានាថា ជំងឺអេដស៍ លែងជាការគំរាមកំហែងសុខភាពសាធារណៈចាប់ពីឆ្នាំ២០២៨។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក និងបញ្ចប់នៅវេលាម៉ោង ១១:៣០នាទីព្រឹក ថ្ងៃខែឆ្នាំដដែលប្រកបដោយលទ្ធផលផ្លែផ្កា។ ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** បានជូនពរដល់សមាជិកអង្គប្រជុំឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃចន្ទ ៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ

**បណ្ឌិត ឈឹម មិនជារ៉េត**

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

វេជ្ជ. ហួត សេរីរដ្ឋ

អ្នកធ្វើរបាយការណ៍

ស៊ុំ ផល្លា